**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...៥៧០...សហវ.ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ ២០១៧

# ប្រកាស

# ស្តីពី

# ការផ្តល់សេវាសាធារណៈ

# របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការដំឡើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ៥៨៥ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២៩៨ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៩ ស្តីពីការកែសម្រួល ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានលទ្ធកម្មសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ ប្រក.ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- សារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១** :

អនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងនាយកដ្ឋានលទ្ធកម្មសាធារណៈ) អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

កម្រងសេវាសាធារណៈនេះ មានបញ្ជាក់លម្អិតអំពីតម្លៃសេវា រយៈពេលផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយនឹងប្រកាសនេះ។

**ប្រការ ២** :

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបិទផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវា ក្នុងនោះរួមមាន ៖ តារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីសម្រាប់ការផ្តល់សេវា ពាក់ព័ន្ធនឹងការប្រមូលចំណូលខាងលើនេះ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងដោយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬមានការយកកម្រៃលើសការកំណត់ ឬមានការយឺតយ៉ាវ ជាដើម។

**ប្រការ ៣** :

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចប្រមូលចំណូល ទទួលខុសត្រូវប្រាក់ចំណូលដែលប្រមូលបាន និងបង់ប្រាក់ចំណូលចូលថវិកាជាតិ ក្នុងនោះ ត្រូវចុះកិច្ចបញ្ជិកាគណនេយ្យ ស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមជានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាថវិកា ព្រមទាំងធ្វើសលាកប័ត្រចំណូល។

**ប្រការ ៤** :

ការបែងចែកភារកិច្ចលើការគ្រប់គ្រង ការប្រមូលចំណូល ពីការផ្តល់សេវាសាធារណៈ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៥** :

រាល់ការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់មកជាមួយប្រកាសនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបានបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៦** :

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលាតាមការកំណត់។

**ប្រការ ៧** :

អង្គភាពប្រមូលចំណូលក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដើម្បីផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ ៨** :

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះ អាចកែប្រែបាន តាមការចាំបាច់តាមរយៈប្រកាស។

**ប្រការ ៩ :**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០ :**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អាត ឈន់**

ចម្លងជូន:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា

«ដើម្បីជូនជ្រាប»
- ដូចប្រការ ១០ «ដើម្បីអនុវត្ត»
- ឯកសារ - កាលប្បវត្តិ

# តារាងឧបសម្ព័ន្ធ
## ភ្ជាប់ទៅនឹងប្រកាសលេខ ៩៧០ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២
## ស្ដីពីការផ្ដល់សេវាសាធារណៈ របស់អង្គភាពក្រោមឱវាទរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### I. អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

| ល.រ | បរិយាយ | ប្រាក់ពន្ធ | តម្លៃសេវា | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| 1 | កម្រៃបែបបទគយ ( Customs Processing Fee - CPF ) | | | | |
| | - មួយកុងតឺន័រ 20ហ្វីតឡើង | 60,000 រៀល | 0 រៀល | 1-2ថ្ងៃ | |
| | - មួយប្រតិវេទន៍គយផលិតផលតេលសិលា | 60,000 រៀល | 0 រៀល | 1-2ថ្ងៃ | |
| | - មួយប្រតិវេទន៍គយទំនិញមិនផ្ទុកក្នុងកុងតឺន័រ ឬផ្ទុកក្នុងកុងតឺន័រតូចជាង 20ហ្វីត | 40,000 រៀល | 0 រៀល | 1-2ថ្ងៃ | |
| 2 | កម្រៃត្រួតពិនិត្យកុងតឺន័រតាមប្រព័ន្ធ TH-SCAN | | | | |
| | - មួយកុងតឺន័រក្រោម 40ហ្វីត | 25 ដុល្លារ | 0 រៀល | 1-2ថ្ងៃ | |
| | - មួយកុងតឺន័រចាប់ពី 40ហ្វីតឡើង | 40 ដុល្លារ | 0 រៀល | 1-2ថ្ងៃ | |
| 3 | កម្រៃអាជ្ញាប័ណ្ណសន្និធិគយបណ្ដោះអាសន្ន( ក្នុងមួយឆ្នាំ ) | 20,000,000 រៀល | 0 រៀល | 1-2ថ្ងៃ | 1ឆ្នាំ |
| 4 | កម្រៃស្ដុកទំនិញក្នុងសន្និធិគយបណ្ដោះអាសន្នហួសកាលកំណត់ ( ក្នុងមួយថ្ងៃ ) | 0.1% លើតម្លៃគិតពន្ធគយ | 0 រៀល | ភ្លាមៗ | សំចតលើស 30ថ្ងៃ នៅតាមអាកាសយានដ្ឋាន និងលើស 45ថ្ងៃ នៅក្រៅអាកាសយានដ្ឋាន |

| ល.រ | បរិយាយ | ប្រាក់ពន្ធ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| 5 | កម្រៃឆ្លងកាត់ | | | | |
| | - គោ ក្របី និងសេះរស់ (ក្នុងមួយក្បាល) | 20,000 រៀល | 0 រៀល | ភ្លាមៗ | |
| | - ជ្រូក ចៀម និងពពែរស់ (ក្នុងមួយក្បាល) | 5,000 រៀល | 0 រៀល | ភ្លាមៗ | |
| | - សត្វស្លាប (មាន់ ទា.........) (ក្នុងមួយគីឡូក្រាម) | 500 រៀល | 0 រៀល | ភ្លាមៗ | |
| | - ផលិតផលជលផល (ក្នុងមួយគីឡូក្រាម) | 500 រៀល | 0 រៀល | ភ្លាមៗ | |
| 6 | តម្លៃទំនិញនាំចូលសម្រាប់លក់ក្នុងអាគាររួចពន្ធ (DUTY FREE SHOP) | ១០% លើតម្លៃគិតពន្ធគយ | 0 រៀល | 1-2ថ្ងៃ | |
| 7 | លក់ប្រតិវេទន៍គយ (ក្នុងមួយលេខ) | 0 រៀល | 15,000 រៀល | ភ្លាមៗ | |
| 8 | លក់លតាប័ត្ររថយន្ត (ក្នុងមួយលេខ) | 0 រៀល | 30,000 រៀល | 1-2ថ្ងៃ | |
| 9 | លក់ត្រាពន្ធគយ (ក្នុងមួយសន្លឹក) | 0 រៀល | 50 រៀល | 1-2ថ្ងៃ | |
| 10 | លក់តែមប្រើអាករ(បិទលើកញ្ចប់បារី) (ក្នុងមួយសន្លឹក) | 0 រៀល | 4.2 រៀល | 1-2ថ្ងៃ | |
| 11 | លក់លិខិតអនុញ្ញាតដឹកជញ្ជូន ឬស្តុក (ក្នុងមួយសន្លឹក) | 0 រៀល | 500 រៀល | ភ្លាមៗ | |
| 12 | លក់សៀលកុងតឺន័រ (ក្នុងមួយគ្រាប់) | 0 រៀល | 8,000 រៀល | 1-2ថ្ងៃ | |

## II. អគ្គនាយកដ្ឋានពន្ធដារ

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 1 | សេវាចុះបញ្ជីសហគ្រាស<br>- សន្លឹកប័ណ្ណប៉ាតង់ប្រចាំឆ្នាំ<br>- សំណុំឯកសារចុះបញ្ជីរួមទាំងសលាកប័ត្រព័ត៌មាន<br>- វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម | 0 រៀល | 7-10ថ្ងៃ | គ្មានកាលកំណត់ រហូតបិទសហគ្រាស |
| 2 | សេវាទទួលលិខិតប្រកាសពន្ធប្រចាំខែក្នុងរបបស្វ័យប្រកាស<br>- ពន្ធលើប្រាក់បៀវត្ស<br>- ពន្ធកាត់ទុក<br>- អាករលើតម្លៃបន្ថែម<br>- ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ/អាករពិសេសលើទំនិញ និងសេវាមួយចំនួន/អាករលើការស្នាក់នៅ/អាករសម្រាប់បំភ្លឺសាធារណៈ/ និងពន្ធអាករផ្សេងៗទៀត | 0 រៀល | 1ថ្ងៃ (បើបង់ប្រាក់នៅធនាគាររួច) | 1ខែ |
| 3 | សេវាទទួលលិខិតប្រកាសពន្ធប្រចាំឆ្នាំក្នុងរបបស្វ័យប្រកាស<br><br>- ពន្ធលើប្រាក់ចំណេញ<br>- ពន្ធប៉ាតង់ | 0 រៀល | (បើបង់ប្រាក់នៅធនាគាររួច)<br>1ថ្ងៃ<br>3-7ថ្ងៃ | 1ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 4 | សេវាទទួលលិខិតប្រកាសពន្ធក្នុងរបបម៉ៅការ<br>- អាករលើផលរបរ<br>- ពន្ធលើប្រាក់ចំណេញ<br>- ពន្ធប៉ាតង់ | 0 រៀល | 1ថ្ងៃ | 3-6-12ខែ |
| 5 | ពន្ធលើអចលនទ្រព្យ | 0 រៀល | ភ្លាមៗ | 1ឆ្នាំ |
| 6 | ពន្ធលើថ្លៃឈ្នួលផ្ទះ និងដី | 0 រៀល | ភ្លាមៗ | តាមកិច្ចសន្យា |
| 7 | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | 0 រៀល | 1-2ថ្ងៃ | 1ឆ្នាំ |
| 8 | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ | 0 រៀល | ភ្លាមៗ | 1ឆ្នាំ |
| 9 | ពន្ធតែមប្រ៊ី (ផ្លាកផ្សាយពាណិជ្ជកម្ម/ផ្លាកយីហោ) | 0 រៀល | ភ្លាមៗ | 1ឆ្នាំ |
| 10 | ពន្ធសត្តឃាត | 0 រៀល | ភ្លាមៗ | 1ខែ |
| 11 | អាករលើការស្នាក់នៅ «របបម៉ៅការ» | 0 រៀល | ភ្លាមៗ | 1ខែ |
| 12 | អាករបំភ្លឺសាធារណៈ «របបម៉ៅការ» | 0 រៀល | ភ្លាមៗ | 1ខែ |
| 13 | ពន្ធប្រថាប់ត្រាលើឯកសារគតិយុត្តិ<br>- លិខិតស្តីពីការបង្កើតក្រុមហ៊ុន | 0 រៀល | 1-3ថ្ងៃ | |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 14 | ពន្ធប្រថាប់ត្រាលើឯកសារគតិយុត្តិ<br>- លិខិតស្ដីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា<br>- លិខិតស្ដីពីការរំសាយក្រុមហ៊ុន<br>- កិច្ចសន្យាដេញថ្លៃផ្គត់ផ្គង់ | 0 រៀល | 1-3ថ្ងៃ (បន្ទាប់ពីលទ្ធផលសវនកម្ម) | |
| 15 | ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិអចលនទ្រព្យ | 0 រៀល | 5-10ថ្ងៃ | |
| 16 | ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានយន្ត | 0 រៀល | 2-5ថ្ងៃ | |
| 17 | សេវាបញ្ជាក់កាតព្វកិច្ចសារពើពន្ធ | 0 រៀល | 1-3ថ្ងៃ (បន្ទាប់ពីលទ្ធផលសវនកម្ម) | |
| 18 | សេវាប្រឹក្សាអំពីនីតិវិធីសារពើពន្ធ | 0 រៀល | | |

III. **នាយកដ្ឋានលទ្ធកម្មសាធារណៈ**

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| 1 | ថ្លៃឈ្នួលចុះបញ្ជីលើកដំបូង | | | |
| | - ប្រភេទ តូច | 100,000 រៀល | 21ថ្ងៃ | 2ឆ្នាំ |
| | - ប្រភេទ មធ្យម | 200,000 រៀល | 21ថ្ងៃ | 2ឆ្នាំ |
| | - ប្រភេទ ធំ | 300,000 រៀល | 21ថ្ងៃ | 2ឆ្នាំ |
| 2 | ថ្លៃឈ្នួលចុះបញ្ជីបន្ត | | | |
| | - ប្រភេទ តូច | 80,000 រៀល | 21ថ្ងៃ | 2ឆ្នាំ |
| | - ប្រភេទ មធ្យម | 140,000 រៀល | 21ថ្ងៃ | 2ឆ្នាំ |
| | - ប្រភេទ ធំ | 200,000 រៀល | 21ថ្ងៃ | 2ឆ្នាំ |
| 3 | ថ្លៃឈ្នួលសុំដំឡើងឋានៈប្រភេទ | | | |
| | - ពីប្រភេទតូច ឡើងទៅ ប្រភេទមធ្យម | 150,000 រៀល | 21ថ្ងៃ | 2ឆ្នាំ |
| | - ពីប្រភេទមធ្យម ឡើងទៅ ប្រភេទធំ | 250,000 រៀល | 21ថ្ងៃ | 2ឆ្នាំ |
| 4 | ថ្លៃឈ្នួលបន្ថែមឈ្មោះចំណាត់ថ្នាក់ | | | |
| | - ប្រភេទ តូច | 80,000 រៀល | 21ថ្ងៃ | 2ឆ្នាំ |
| | - ប្រភេទ មធ្យម | 160,000 រៀល | 21ថ្ងៃ | 2ឆ្នាំ |
| | - ប្រភេទ ធំ | 240,000 រៀល | 21ថ្ងៃ | 2ឆ្នាំ |

## IV. នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ក | ការិយាល័យគ្រប់គ្រងការជួញដូរអចលនវត្ថុ | | | |
| 1 | ថ្លៃអាជ្ញាប័ណ្ណសេវាអចលនវត្ថុ | 500,000 រៀល | 45ថ្ងៃ | 1ឆ្នាំ |
| 2 | ថ្លៃអាជ្ញាប័ណ្ណវាយតម្លៃអចលនវត្ថុ | 500,000 រៀល | 45ថ្ងៃ | 1ឆ្នាំ |
| 3 | ថ្លៃវិញ្ញាបនបត្រសេវាអចលនវត្ថុ | 200,000 រៀល | 45ថ្ងៃ | 1ឆ្នាំ |
| 4 | ថ្លៃវិញ្ញាបនបត្រវាយតម្លៃអចលនវត្ថុ | 200,000 រៀល | 45ថ្ងៃ | 1ឆ្នាំ |
| 5 | ថ្លៃអាជ្ញាប័ណ្ណវិស្វករឯករាជ្យ | 2,000,000 រៀល | 45ថ្ងៃ | 1ឆ្នាំ |
| 6 | ថ្លៃអាជ្ញាប័ណ្ណអភិវឌ្ឍន៍អចលនវត្ថុ | តាមទំហំគម្រោង | 45ថ្ងៃ | តាមទំហំ |
| 7 | ថ្លៃបន្តអាជ្ញាប័ណ្ណ និងវិញ្ញាបនបត្រខាងលើទាំងអស់ | ដូចគ្នានឹងស្នើសុំថ្មី | 45ថ្ងៃ | |
| ខ | ការិយាល័យកាស៊ីណូ | | | |
| 1 | ថ្លៃអាជ្ញាប័ណ្ណកាស៊ីណូ | 30,000 ដុល្លារ | 30ថ្ងៃ | 1ឆ្នាំ |
| 2 | ថ្លៃបន្តសុពលភាពអាជ្ញាប័ណ្ណកាស៊ីណូ | 30,000 ដុល្លារ | 30ថ្ងៃ | 1ឆ្នាំ |
| 3 | ផ្ទេរសិទ្ធអាជ្ញាប័ណ្ណកាស៊ីណូ | 100,000,000 រៀល | 30ថ្ងៃ | អចិន្ត្រៃយ៍ |
| គ | ការិយាល័យគ្រប់គ្រងអាជីវកម្មទទួលបញ្ចាំ | | | |
| 1 | ថ្លៃអាជ្ញាប័ណ្ណអាជីវកម្មទទួលបញ្ចាំ | 2,000,000 រៀល | 45ថ្ងៃ | 1ឆ្នាំ |
| 2 | ថ្លៃអាជ្ញាប័ណ្ណអាជីវកម្មទទួលប្រាតិភោគដោយអនុប្បទាន | 1,000,000 រៀល | 45ថ្ងៃ | 1ឆ្នាំ |
| 3 | ថ្លៃអាជ្ញាប័ណ្ណទទួលបញ្ចាំ និងទទួលប្រាតិភោគដោយអនុប្បទាន | 3,000,000 រៀល | 45ថ្ងៃ | 1ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ឃ | **ការិយាល័យធានារ៉ាប់រង** | | | |
| 1 | ថ្លៃអាជ្ញាប័ណ្ណក្រុមហ៊ុនធានារ៉ាប់រងទូទៅ ឬក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត | 50,000,000 រៀល | 45ថ្ងៃ | 5ឆ្នាំ |
| 2 | ថ្លៃបន្តសុពលភាពអាជ្ញាប័ណ្ណក្រុមហ៊ុនធានារ៉ាប់រងទូទៅ ឬក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត | 50,000,000 រៀល | 45ថ្ងៃ | 3ឆ្នាំ |
| 3 | ថ្លៃអាជ្ញាប័ណ្ណ ឬថ្លៃបន្តសុពលភាពអាជ្ញាប័ណ្ណជើងសារធានារ៉ាប់រង | 4,000,000 រៀល | 45ថ្ងៃ | 1ឆ្នាំ |
| 4 | ថ្លៃអាជ្ញាប័ណ្ណ ឬថ្លៃបន្តសុពលភាពអាជ្ញាប័ណ្ណភ្នាក់ងារធានារ៉ាប់រង | 3,000,000 រៀល | 45ថ្ងៃ | 3ឆ្នាំ |
| 5 | ថ្លៃអាជ្ញាប័ណ្ណ ឬថ្លៃបន្តសុពលភាពអាជ្ញាប័ណ្ណក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រង | 3,000,000 រៀល | 45ថ្ងៃ | 3ឆ្នាំ |
| 6 | ថ្លៃអាជ្ញាប័ណ្ណ ឬថ្លៃបន្តសុពលភាពអាជ្ញាប័ណ្ណក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច | 5,000,000 រៀល | 45ថ្ងៃ | 1ឆ្នាំ |
| 7 | ថ្លៃវិញ្ញាបនបត្រសាខា ឬថ្លៃបន្តសុពលភាពវិញ្ញាបនបត្រសាខាក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច | 5,000,000 រៀល | 45ថ្ងៃ | 1ឆ្នាំ |
| ង | **ការិយាល័យមីក្រូហិរញ្ញវត្ថុ និងសហគ្រាសធុនតូច និងមធ្យម** | | | |
| 1 | ការប្រាក់នៃការផ្ដល់ឥណទានដោយប្រើប្រាស់មូលនិធិទ្រទ្រង់ និងអភិវឌ្ឍន៍វិស័យកសិកម្ម | 6% ទៅ 7% | 30ថ្ងៃ | - ខ្លី 1ឆ្នាំ<br>- វែង 3-5ឆ្នាំ |

| ល.រ | បរិយាយ | តម្លៃសេវា | រយៈពេលផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|
| ច | ការិយាល័យគ្រប់គ្រងល្បែងភ្នាល់ | | | |
| 1 | ថ្លៃអាជ្ញាប័ណ្ណឆ្នោត | 40,000,000 រៀល | 30ថ្ងៃ | 1ឆ្នាំ |
| 2 | ថ្លៃវិញ្ញាបនបត្រឆ្នោត ( សាខា ) | 10,000,000 រៀល | 30ថ្ងៃ | 1ឆ្នាំ |
| 3 | ថ្លៃប្រភេទឆ្នោត | 20,000,000 រៀល | 30ថ្ងៃ | អចិន្ត្រៃយ៍ |
| 4 | ថ្លៃផ្ទេរសិទ្ធិកាន់កាប់អាជ្ញាប័ណ្ណ | 150,000,000 រៀល | 30ថ្ងៃ | អចិន្ត្រៃយ៍ |